00636535

E20

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ |
| ភាគីដាក់ឯកសារ: | សហមេធាវីរបស់លោក អៀង សារី |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១១ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 01 / 2011
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

## ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូ ឧត្តរ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") តទៅនេះសុំស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យដំណើរការសវនាការរយៈពេលកន្លះថ្ងៃ ក្នុងអំឡុងពេលជំនុំជម្រះក្ដីលើសំណុំរឿង ០០២ ។ ញត្តិនេះគឺត្រូវធ្វើឡើងជាចាំបាច់ ពីព្រោះលោក អៀង សារី មានសិទ្ធិមានវត្តមាននៅសវនាការជំនុំជម្រះក្ដី និងមានបំណងអនុវត្តសិទ្ធិនេះ តែដោយសារអាយុ និងសុខភាពទ្រុឌទ្រោមរបស់គាត់ បានរារាំងគាត់មិនឱ្យអង្គុយនៅក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបាន ។ លោក អៀង សារី មិនជ្រើសរើសប្រើប្រាស់បច្ចេកវិទ្យាការចូលរួមពីចម្ងាយ (វីដេអូលីង) ជំនួសឱ្យវត្តមានរបស់គាត់នៅពេលសវនាការជំនុំជម្រះក្ដីនោះទេ។ មេធាវីការពារក្ដីស្នើថាបញ្ហានេះត្រូវតែបានដោះស្រាយនៅកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនៅខែមីនា ឬ ខែមេសា ឆ្នាំ២០១១ ខាងមុខនេះ[1] ។

## I. ច្បាប់នៅជាធរមាន

១. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ" ។

២. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" ។

៣. មាត្រា ៣៥ថ្មី (ខ)និង(ឃ)នៃច្បាប់បង្កើត អវតក ចែងថា:

> ជនជាប់ចោទណាក៏ដោយ ត្រូវទុកជានមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃអនុសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធនយោបាយ ឆ្នាំ១៩៥៦...ខ) មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសរើសដោយខ្លួនឯង,....ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ និងទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួល

---

[1] សារអេឡិចត្រូនិកពីអ្នកនាង Susan Lamb អ្នកសម្របសម្រួលជាន់ខ្ពស់របស់តុលាការ ផ្ញើជូនក្រុមមេធាវីការពារក្ដី កម្មវត្ថុ: ការទំនាក់ទំនងទៅភាគី ជំនួសមុខឱ្យអង្គជំនុំជម្រះសាលាដំបូង-ក្រុម អៀង សារី ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១១ ។

00636537



ដោយខ្លួនឯង...[2] ។

៤. វិធាន ៨១(៥) នៃវិធានផ្ទៃក្នុងចែងថា:

ប្រសិនបើមានមូលហេតុពីស្ថានភាពសុខភាព ឬមូលហេតុធ្ងន់ធ្ងរដែលធ្វើឱ្យជនជាប់ចោទមិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានទេ អង្គជំនុំជម្រះសាលាដំបូងអាចបន្តនីតិវិធីដោយមានវត្តមានជនជាប់ចោទបាន ដោយមានការយល់ព្រមពីជនជាប់ចោទ ។ ក្នុងករណីនេះ ជនជាប់ចោទអាចត្រូវបានការពារនៅក្នុងកិច្ចដំណើរការនីតិវិធីដោយមេធាវីរបស់ខ្លួន ។ នៅពេលដែលជនជាប់ចោទបដិសេធមិនធ្វើការជ្រើសរើសមេធាវី អង្គជំនុំជម្រះសាលាដំបូងត្រូវបង្គាប់ឱ្យមានមេធាវីការពារជនជាប់ចោទ និងស្នើឱ្យអង្គភាពគាំពារការការពារក្ដី ធ្វើការចាត់តាំងមេធាវីសម្រាប់ជនជាប់ចោទ ពីបញ្ជីដែលមានចែងនៅក្នុងវិធាន ១១ ។ ជនជាប់ចោទអាចស្នើសុំតាមដាននីតិវិធីផងដែរ តាមរយៈឧបករណ៍សោតទស្សន៍ដែលសមស្រប ។ ប្រសិនបើការសួរចម្លើយលើជនជាប់ចោទត្រូវការជាចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យជនជាប់ចោទផ្ដល់ចម្លើយពីកន្លែងរបស់ខ្លួន តាមរយៈឧបករណ៍សោតទស្សន៍ដែលសមស្រប ។ អង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការសួរចម្លើយដែលខ្លួនត្រូវសួរ ដោយមានវត្តមានសហព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវីរបស់ជនជាប់ចោទ លើកលែងតែបោះបង់សិទ្ធិ ដែលត្រូវមានជំនួយពីមេធាវី ។ ការសាកសួរចម្លើយត្រូវតកត់ត្រាចូលក្នុងកំណត់ហេតុសវនាការ[3]។

៥. មាត្រា ១៤(៣)(ខ) និង(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ចែងថា "ក្នុងសម្រេចចោទប្រកាន់មកលើពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា ដោយស្មើគ្នាយ៉ាងពេញលេញ... ខ) ត្រូវមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទំនាក់ទំនងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង... ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន.."។

## II. អំណះអំណាង

---

[2] បញ្ជាក់បន្ថែម ។

[3] បញ្ជាក់បន្ថែម ។

៦. លោក អៀង សារី មានសិទ្ធិមានវត្តមាននៅសវនាការជំនុំជម្រះក្តី ដែលផ្តល់ឱ្យគាត់ដោយរដ្ឋធម្មនុញ្ញកម្ពុជា[4] ច្បាប់បង្កើត អវតក[5] វិធានផ្ទៃក្នុង[6] និងកតិការសញ្ញា ICCPR[7] ។ លោក អៀង សារី មានបំណងអនុវត្តសិទ្ធិនេះ ។ ដោយសារតែអាយុ និងបញ្ហាសុខភាពរបស់គាត់បានរារាំងលោក អៀង សារី មិនអាចអង្គុយនៅក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបានឡើយ ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ ព្រមជាមួយការសំរាកយ៉ាងហោចណាស់មួយដងដែលមានរយៈពេល ១៥ នាទីនៅពាក់កណ្តាលសវនាការ ។

៧. លោក អៀង សារី មានបញ្ហាផ្នែកខ្នងរបស់គាត់ ដែលបង្កឱ្យមានការចុកចាប់យ៉ាងខ្លាំងនៅពេលអង្គុយក្នុងរយៈពេលយូរ ។ គាត់មានបញ្ហាទឹកនោមដែលតម្រូវឱ្យគាត់ទៅបន្ទប់ទឹកជាញឹកញាប់ ។ គាត់ក៏មានបញ្ហាក្នុងការរក្សាថាមពលរបស់គាត់និងការផ្ចិតផ្ចង់ផ្តោតអារម្មណ៍ក្នុងរយៈពេលយូរ[8]។ បញ្ហាទាំងនេះ តម្រូវថារាល់ពេលសវនាការជំនុំជម្រះក្តីត្រូវមានរយៈពេលខ្លី ដើម្បីសម្រួលដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមាននៅសវនាការ ។

---

[4] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ""ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" ។ សិទ្ធិត្រូវតែមានវត្តមាននៅសវនាការ គឺជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ដោយមាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញា ICCPR ដែលប្រទេសកម្ពុជាជាហត្ថលេខីមួយដែរ ។

[5] ច្បាប់បង្កើត អវតក មាត្រា ៣៥ថ្មី(ឃ) ។

[6] វិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ។

[7] កតិកាសញ្ញា ICCPR មាត្រា ១៤(៣)(ឃ) ។

[8] មេធាវីការពារក្តីមិនអាចជួបសំណេះសំណាលជាមួយលោក អៀង សារី ឱ្យលើសពីរយៈមួយម៉ោងបានទេ ហើយក៏អាចជួបគាត់លើសពីរយៈពេល ២ ម៉ោងក្នុងមួយថ្ងៃបានដែរ ដោយសារតែគាត់មានការលំបាកក្នុងការអង្គុយរយៈពេលយូរ និងរកឃើញថាគាត់មានការយកចិត្តទុកដាក់យ៉ាងខ្លាំង ដែលធ្វើឱ្យគាត់នឿយហត់ ហើយគាត់មិនអាចជួយដល់ក្រុមការពារក្តីប្រកបដោយប្រសិទ្ធិភាពបានទេ នៅពេលការជួបណាមួយមានរយៈពេលយូរនោះ ។ គាត់តែងតែទៅបន្ទប់ទឹកពីរដងក្នុងអំឡុងពេលនៃការជួបដែលមានរយៈពេលមួយម៉ោង ។ សូមផលដែរ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-, លិខិតពីមេធាវីការពារក្តី អៀង សារី ផ្ញើជូនសហចៅក្រមស៊ើបអង្កេត កម្មវត្ថុ: សំណើសុំសម្ភាសន៍លោក អៀង សារី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៨ នៅក្នុងបន្ទប់របស់គាត់ នៅមន្ទីរឃុំឃាំង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨, A212/1, ERN: 00219033-00219035; *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-, លិខិតពីសហចៅក្រមស៊ើបអង្កេត ផ្ញើទៅក្រុមការពារក្តី អៀង សារី កម្មវត្ថុ: ការផ្លាស់ប្តូរទីកន្លែងសម្ភាស អៀង សារី ក្រោមវិធាន ៦៣(៨) ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៨ A212/2, ERN: 00218954

៨. វាត្រូវបានបង្ហាញយ៉ាងច្បាស់ថាការអនុវត្តសិទ្ធិនីតិវិធីរបស់ជនជាប់ចោទបញ្ជាក់ពីកម្រិតគ្រប់គ្រាន់នៃសមត្ថភាពខាងផ្លូវកាយនិងស្មារតី[9]។ តុលាការ ICTY បានយល់ឃើញថាសិទ្ធិត្រូវតែមានវត្តមាន "ហាក់ដូចជាដើម្បីធានាវត្តមានជនជាប់ចោទម្នាក់ <u>ដែលអាចជួយដល់តុលាការក្នុងការបង្ហាញការការពាររបស់គាត់</u>"[10] ។ "ការពឹងពាក់មេធាវីតម្រូវ...ថាជនជាប់ចោទមានសមត្ថភាពពន្យល់ប្រាប់មេធាវីយ៉ាងមានប្រសិទ្ធិភាព..."[11]។ ការខ្វះសមត្ថភាពណែនាំមេធាវីអាចធ្វើឱ្យជនជាប់ចោទមិនមានសម្បទាក្នុងការចូលរួមសវនាការ[12]។ ដើម្បីចូលរួមនៅក្នុងនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងគាត់ប្រកបដោយប្រសិទ្ធិភាព លោក អៀង សារី ត្រូវតែអាចស្តាប់បាន និងតាមដានដំណើរការនីតិវិធី និងអាចជួយដល់មេធាវីរបស់គាត់[13] ។ ប្រសិនបើសមត្ថភាពខាងបញ្ញាស្មារតីរបស់លោក អៀង សារី ធ្លាក់ចុះពេញមួយថ្ងៃ ដោយសារតែការចូលរួមសវនាការពេញមួយថ្ងៃ ការណ៍នេះអាចរារាំងគាត់មិនឱ្យទាក់ទងដោយប្រសិទ្ធិភាពជាមួយមេធាវី ដែលជាការរំលោភសិទ្ធជាមូលដ្ឋានរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

៩. មេធាវីការពារក្តីទទួលស្គាល់ថាការដំណើរការសវនាការជំនុំជម្រះក្តីកន្លះថ្ងៃ នឹងប្រើពេលយូរជាងសវនាការជំនុំជម្រះក្តីពេញមួយថ្ងៃ ។ មេធាវីការពារក្តីក៏ទទួលស្គាល់ដែរថាជនជាប់ចោទ<u>ទាំងអស់</u>មានសិទ្ធិក្នុងការកាត់សេចក្តីក្នុងរយៈពេលសមរម្យមួយ[14] ។ ការដំណើរការសវនាការជំនុំជម្រះក្តីដែលមានរយៈពេលកន្លះថ្ងៃ នឹងមិនបង្កឱ្យមានការអូសបន្លាយពេលវេលាដោយមិនសមរម្យឡើយ។ នៅតុលាការ ICTY ដែលបានជំនុំជម្រះក្តីជាច្រើនករណីដែលមានទំហំនិងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នានឹងសំណុំរឿង ០០២ នេះដែរ ការដំណើរការសវនាការជំនុំជម្រះក្តីកន្លះថ្ងៃ គឺជាការអនុវត្តធម្មតា ។ បើទោះបីជាសវនាការជំនុំជម្រះក្តីកន្លះថ្ងៃអាចត្រូវបានគេចាត់ទុកថា ប៉ះពាល់ដល់

---

[9] សូមមើលករណីរដ្ឋអាជ្ញា តទល់ជាមួយ *Strugar*, IT-01-42-T, សេចក្តីសម្រេចលើញាតិរបស់មេធាវីការពារក្តី សុំបញ្ចប់នីតិវិធី ("សេចក្តីសម្រេច *Strugar* ") ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ នៅកថាខណ្ឌទី២១ ។

[10] ដូចខាងលើ នៅកថាខណ្ឌទី ២២ ។

[11] រណីរដ្ឋអាជ្ញា តទល់ជាមួយ *Kovačević*, IT-01-42/2-I អត្ថបទសាធារណៈនៃសេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ នៅកថាខណ្ឌទី ២៣ ។

[12] សេចក្តីសម្រេច *Strugar* នៅកថាខណ្ឌទី ៣៥-៣៦ ។

[13] សូមមើល *Barbera, Messegue & Jabardo តទល់ជាមួយប្រទេសអេស្បាញ* តុលាការ ECHR ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៨៨ នៅកថាខណ្ឌទី ៧០ ។ ករណី *Makhfi* តទល់ជាមួយប្រទេសបារាំង តុលាការ ECHR ចុះថ្ងៃទី១៩ ខែតុលា នៅកថាខណ្ឌទី ៤០ ករណី *Stanford* តទល់ជាមួយប្រទេសអង់គ្លេស តុលាការ ECHR ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៤ នៅកថាខណ្ឌទី២៦ ។

[14] សូមមើល ឧទាហរណ៍មាត្រា ៣៥ ថ្មី(គ) និង និងវិធាន ២១(៤) នៃវិធានផ្ទៃក្នុង ។

សិទ្ធិរបស់ជនជាប់ចោទដទៃទៀត ក្នុងការទទួលបានការកាត់សេចក្តី ក្នុងរយៈពេលសមរម្យ ក៏ផលប្រយោជន៍ប្រកួតប្រជែង ត្រូវតែបានពិចារណាដោយគិតពីគោលការណ៍សមាមាត្រដែរ ។ អនុលោមទៅតាមគោលការណ៍នេះ “រាល់ការរឹតបន្តឹងលើសិទ្ធិជាមូលដ្ឋាន ត្រូវតែយកមកប្រើប្រាស់នៅក្នុងទិសដៅសំខាន់គ្រប់គ្រាន់ និងត្រូវតែបន្ធូរបន្ថយសិទ្ធិមិនអោយលើសពីភាពចាំបាច់ដើម្បីសម្រេចទិសដៅនេះឡើយ”[15] ។ នៅករណីណាក៏ដោយ ក៏ជនជាប់ចោទដទៃទៀតអាចទទួលបានផលប្រយោជន៍ពីសវនាការជំនុំជម្រះក្តីកន្លះថ្ងៃនេះដែរ ដោយសារបញ្ហាសុខភាពរបស់ពួកគេ ។ ការបង្ខំលោក អៀង សារី ឬ ជនជាប់ចោទដទៃទៀតឱ្យចូលរួមសវនាការពេញមួយថ្ងៃ នៅពេលដែលពួកគេមិនមានសុខភាពល្អគ្រប់គ្រាន់ នោះការធ្វើដូច្នេះនឹងបង្កឱ្យមានការអូសបន្លាយពេលវេលានៅថ្ងៃអនាគតតែប៉ុណ្ណោះ ។

១០. មេធាវីការពារក្តីបានទទួលដំណឹងថា ឧបករណ៍ វីដេអូលីង ត្រូវបានគេបំពាក់ក្នុងបន្ទប់រក្សាជនជាប់ចោទ (holding cell) និងអាចបំពាក់ក្នុងមន្ទីរឃុំឃាំងទៀតផង ក្នុងករណីជនជាប់ចោទចង់តាមដានដំណើរការជំនុំជម្រះក្តីតាមរយៈ វីដេអូលីង [16]។ លោក អៀង សារី មិនចង់ប្រើប្រព័ន្ធបច្ចេកវិទ្យាបែបនេះ ជំនួសឱ្យសិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅសវនាការជំនុំជម្រះក្តី នោះទេ។ លោក អៀង សារី មានបំណងចូលរួមយ៉ាងសកម្ម ដើម្បីជួយដល់កិច្ចការពារក្តីរបស់គាត់ ។ ដូច្នេះ លោក អៀង សារី ត្រូវតែអាចទំនាក់ទំនងជាមួយសហមេធាវីរបស់គាត់ដោយផ្ទាល់ក្នុងអំឡុងពេលសវនាការជំនុំជម្រះក្តី។

១១. សិទ្ធិរបស់លោក អៀង សារី ក្នុងការទាក់ទងជាមួយសហមេធាវីការពារក្តីរបស់គាត់ ត្រូវបាន

---

[15] ករណីរដ្ឋអាជ្ញា តទល់ជាមួយ *Stanišić & Simatović*, IT-03-69-AR73.2, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ ប្រឆាំងនឹងសេចក្តីសម្រេចលើអនាគតរបស់ដំណើរការនីតិវិធី ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ (“សាលដីកា *Stanišić* លើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំ”) ។ នៅក្នុងសាលដីកា *Stanišić* អង្គជំនុំជម្រះតុលាការកំពូលច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យការគោរព និងរកឃើញថាអង្គជំនុំជម្រះសាលាដំបូងខកខាន “មិនបានផ្តល់ការថ្លឹងថ្លែងគ្រប់គ្រាន់ចំពោះសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវកាត់ក្តីនៅចំពោះមុខ” ហើយបានកត់ត្រាការថ្លឹងថ្លែងមិនត្រឹមត្រូវចំពោះទិសដៅនៃការដំណើរការនីតិវិធី” ។ ដូចខាងលើ នៅកថាខណ្ឌទី១៨ ។

[16] អនុស្សារណៈអន្តរការិយាល័យបញ្ជូនពីលោក Jonh Downard, អ្នកត្រួតពិនិត្យAV ប្រចាំអង្គភាពគ្រប់គ្រងតុលាការ ទៅកាន់លោក Rupert Abott ប្រធានស្តីទីនៃអង្គភាពគាំពារការការពារក្តី, កម្មវត្ថុៈព័ត៌មានចុងក្រោយស្តីពី ឧបករណ៍វីដេអូលីង, ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០១១ ។

ធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា[17] និងច្បាប់បង្កើត អវតក[18]។ លោក អៀង សារី ត្រូវតែមានវត្តមានក្នុងសាលសវនាការ ដើម្បីទំនាក់ទំនងជាមួយសហមេធាវីរបស់គាត់ក្នុងអំឡុងពេលសវនាការជំនុំជម្រះក្តី ។ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថា លក្ខខណ្ឌនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ("ICCPR") "មិនត្រូវបានគោរពឡើយក្នុងករណីដែល...ជនជាប់ចោទគ្មានឱកាសចូលរួមនីតិវិធីដោយផ្ទាល់ ឬក៏ក្នុងករណីដែលជនជាប់ចោទ មិនអាចពន្យល់ប្រាប់អ្នកតំណាងផ្លូវច្បាប់របស់គាត់ឱ្យបានត្រឹមត្រូវទេនោះ[19]"។ ប្រការដែលថាលោក អៀង សារី មានសហមេធាវីការពារផលប្រយោជន៍របស់គាត់ក្នុងពេលជំនុំជម្រះក្តី មិនអាចប៉ះប៉ូវនឹងអវត្តមានរបស់លោក អៀង សារី ក្នុងពេលសាលសវនាការបានឡើយ លុះត្រាតែលោក អៀង សារី បោះបង់ចោលនូវសិទ្ធិរបស់គាត់មិនចូលរួមសវនាការជំនុំជម្រះដោយផ្ទាល់ ។ លោក អៀង សារី មិនគ្រាន់តែជាអ្នកសង្កេតការនៃការជំនុំជម្រះក្តីនេះទេ ។ ដូចដែលលោក Schomburg អតីតចៅក្រមនៅអង្គជំនុំជម្រះតុលាការកំពូល ICTY/ICTR បានពន្យល់ថា៖ "សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ជនជាប់ចោទ <u>មិនត្រូវក្លាយជាកម្មវត្ថុតែមួយគត់នៃនីតិវិធីព្រហ្មទណ្ឌឡើយ[20]</u>"។

១២. ទោះបីជាលោក អៀង សារី អាចទាក់ទងជាមួយសហមេធាវីរបស់គាត់នៅពេលមើលការជំនុំ

---

[17] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូច មានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

[18] មាត្រា៣៥ ថ្មីនៃច្បាប់ស្តីពីការបង្កើត អវតក ចែងថា៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទ មានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាស្របតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តី ពិសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ... <u>ដើម្បីទាក់ទងមេធាវីការពារក្តីដែលខ្លួនបានជ្រើសរើស</u>... " ( គូសបញ្ជាក់បន្ថែម)។

[19] ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ស្របតាមមាត្រា៥,កថាខណ្ឌទី៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ, លិខិតទំនាក់ទំនងលេខ 289/1988: Panama ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩២, CCPR/C/44/289/1988 (ច្បាប់យុត្តិសាស្ត្រ), កថាខណ្ឌទី៦.៦។

[20] សូមមើលគំនិតជំទាស់ពិសេសរបស់ចៅក្រម Scjomburg ទៅនឹងសិទ្ធិសុំការពារក្តីដោយខ្លួនឯង,កថាខណ្ឌទី៣, ក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Krajišnik*, IT-00-39-A, សេចក្តីសម្រេចលើសំណើសុំការពារក្តីដោយខ្លួនឯងរបស់លោក Momcilo Krajišnik, សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីទាក់ទងនឹងការតែងតាំងមេធាវីដែលមិនមែនជាភាគីនៃរឿងក្តី និងសេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកុម្ភៈ, ថ្ងៃទី១១ ខែ ឧសភា ឆ្នាំ២០០៧ (គូសបញ្ជាក់បន្ថែម)។

ជម្រះក្តីតាមវីដេអូលីងក៏ដោយ[21] ក៏វានៅតែមិនអាចប៉ះប៉ូវសិទ្ធិរបស់គាត់ក្នុងការចូលរួមការជំនុំជម្រះដោយផ្ទាល់ដែរ ប្រសិនជាលោក អៀង សារី មិនបោះបង់សិទ្ធិរបស់គាត់ក្នុងការចូលរួមដោយផ្ទាល់នោះ ។ នៅតុលាការ ICTY និង ICTR ដែលមានការធានាតាមផ្លូវច្បាប់ស្រដៀងគ្នានេះចំពោះសិទ្ធិមានវត្តមាននៅពេលជំនុំជម្រះ សិទ្ធិនេះត្រូវបានគេបកស្រាយថាជាសិទ្ធិត្រូវមានវត្តមានផ្ទាល់ ក្នុងពេលជំនុំជម្រះ[22]។

១៣. ឧទាហរណ៍ ក្នុងរឿងក្តីរវាង *Zigiranyirazo* តទល់នឹងរដ្ឋអាជ្ញា ដោយសារហេតុផលសន្តិសុខ អង្គជំនុំជម្រះសាលាដំបូងនៅតុលាការ ICTR បានអនុញ្ញាតឱ្យសាក្សីផ្តល់សក្ខីកម្មពីប្រទេសហូឡង់ ខណៈពេលដែលចុងចោទ Zigiranyirazo តាមដាននីតិវិធីនេះតាម វីដេអូលីង ពី Arusha។ លោក Zigiranyirazo បានអះអាងថានីតិវិធីនេះបានរំលោភសិទ្ធិរបស់គាត់ក្នុងការមានវត្តនៅសវនាការដោយផ្ទាល់ ដែលសិទ្ធិនេះអាចត្រូវបានបំពេញតែតាមរយៈការមានវត្តមានផ្ទាល់ជាក់ស្តែងតែប៉ុណ្ណោះ[23]។ លោកបានពន្យល់ថា "ការលំបាកនានាដែលបង្កឡើងដោយការផ្តល់ភស្តុតាង និងការទំនាក់ទំនងជាមួយចៅក្រមដោយតាមរូបភាព" គឺមិនអាចឱ្យគាត់អនុវត្តឱ្យបានពេញលេញនូវសិទ្ធិរបស់គាត់ក្នុងការមានវត្តនៅសវនាការជំនុំជម្រះឡើយ[24]។ លោក Zigiranyirazo បានកត់សម្គាល់ថាការប្រើបច្ចេកវិទ្យា វីដេអូលីង មានន័យថាទាំងខ្លួនគាត់ និងមេធាវីនាំមុខរបស់គាត់ដែលស្ថិតនៅទីក្រុង Arusha នៅពេលជំនុំជម្រះនោះ មិនអាចអង្កេត ឬស្តាប់ចៅក្រម ឬសាក្សីបានឡើយ ប្រសិនបើម៉ាស៊ីនថត មិនថតពួកគេទេនោះ ។ ជាលទ្ធផល វីដេអូលីង "បដិសេធពួកគេក្នុងការទំនាក់ទំនងធម្មតាជាមួយនីតិវិធី[25]" ។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រលោក Zigiranyirazo ហើយបានលើកឡើងថា "តាមវិធានទូទៅ ការមានវត្តមាន

---

[21] នៅក្នុងសេចក្តីសម្រេច *Stanišić* បច្ចេកវិទ្យាវីដេអូលីងដែលគេស្នើសុំ រួមបញ្ចូលទាំងបណ្តាញទូរស័ព្ទដែលអនុញ្ញាតឱ្យជនជាប់ចោទទាក់ទងជាមួយមេធាវីការពារក្តីគ្រប់ពេលទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការប្រើបច្ចេកវិទ្យាវីអូអេលីង។ សេចក្តីសម្រេចរបស់ *Stanišić* លើបណ្តឹងឧទ្ធរណ៍បន្ទាន់, កថាខណ្ឌទី១៣, កថាខណ្ឌទី២២។

[22] សូមមើល ឧទាហរណ៍, នៅក្នុងសេចក្តីសម្រេច *Stanišić* លើបណ្តឹងឧទ្ធរណ៍បន្ទាន់, កថាខណ្ឌទី៦, រឿងក្តី *Zigiranyirazo* តទល់នឹងរដ្ឋអាជ្ញា, ICTR-2001-73-AR73, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់, ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៦ ("សេចក្តីសម្រេច *Zigiranyirazo* លើបណ្តឹងឧទ្ធរណ៍បន្ទាន់"), កថាខណ្ឌទី១៣។

[23] សេចក្តីសម្រេច *Zigiranyirazo* លើបណ្តឹងឧទ្ធរណ៍បន្ទាន់, កថាខណ្ឌទី២។

[24] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី១៦។

[25] ដូចជើងទំព័រខាងលើ។

របស់ជនជាប់ចោទនៅចំពោះមុខតុលាការ គឺជាខប្រតិបត្តិមួយក្នុងចំណោមខប្រតិបត្តិជាមូលដ្ឋាន និងទូទៅបំផុតជាច្រើនទៀតនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌដោយយុត្តិធម៌[26]"។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថា "ការចូលរួមសវនាការតាមបច្ចេកវិទ្យា វីដេអូលីង គឺមិនចាត់ទុកថាមានវត្តមានឡើយ[27]" ។ ដូចគ្នានេះដែរ នៅក្នុងករណីបច្ចេកវិទ្យាវី វីដេអូលីង នៅពេលបច្ចុប្បន្ននេះ គឺមិនអាចប៉ះប៉ូវនឹងការមានវត្តមានដោយផ្ទាល់របស់ជនជាប់ចោទនៅសវនាការជំនុំជម្រះបានទេ។ អង្គជំនុំជម្រះ សាលាដំបូង ត្រូវតែទទួលស្គាល់ និងតាក់តែងបទបញ្ញត្តិដ៏សមហេតុផលដើម្បីគោរពសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការមានវត្តមានដោយផ្ទាល់នៅសវនាការជំនុំជម្រះក្តីរបស់គាត់ ។

## III. **ការស្វែងរកដំណោះស្រាយ**

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលទាំងអស់ដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងដំណើរការសវនាការជំនុំជម្រះក្តីកន្លះថ្ងៃ ព្រមជាមួយការសំរាកយ៉ាងហោចណាស់មួយដង ដែលមានរយៈពេល ១៥ នាទី ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកញត្តិនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៩** ខែ **មករា** ឆ្នាំ **២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

---

[26] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១១។

[27] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១២។ អង្គជំនុំជម្រះតុលាការកំពូលពិតជាកត់សម្គាល់ថា សិទ្ធិនេះ គឺមិនមែនជាសិទ្ធិដាច់ខាត ហើយចំនុចនេះមិនត្រូវបានតវ៉ាដោយភាគីទាំងអស់ក្នុងរឿងក្តីទេ។ ដូចជើងទំព័រខាង លើ, កថាខណ្ឌទី១៥។ ស្រដៀងគ្នានេះដែរ ក្នុងសេចក្តីសម្រេច *Stanišić* អង្គជំនុំជម្រះតុលាការកំពូល សង្កេត ឃើញថាសិទ្ធិរបស់ជនជាប់ចោទក្នុងការបង្ហាញវត្តមាននៅពេលជំនុំជម្រះ អាចត្រូវបានកម្រិត ដោយឈលើ "មូលដ្ឋាននៃការរំខានដល់ការជំនុំជម្រះក្តីសំខាន់"។ សេចក្តីសម្រេច *Stanišić* លើបណ្តឹងឧទ្ធរណ៍បន្ទាន់,កថាខណ្ឌទី៦ (គូសបញ្ជាក់បន្ថែម)។ ការកម្រិតរយៈពេលសវនាការជំនុំជម្រះក្តីត្រឹមកន្លះថ្ងៃដោយសារតែជនជាប់ចោទមិនអាចអង្គុយស្តាប់ការជំនុំជម្រះក្តីក្នុងរយៈពេលវែងបាននោះ មិនអាចត្រូវបានគេចាត់ទុកថាជា ការរំខានដល់ការជំនុំជម្រះក្តីសំខាន់បានឡើយ។